ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

*ថ្ងៃព្រហស្បតិ៍ ១១រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០*
*រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៦*

# សេចក្ដីប្រកាសព័ត៌មាន

## គម្រោងវិនិយោគចំនួន៣៧ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ៥៧០លានដុល្លារអាម៉េរិក ត្រូវបានចុះបញ្ជីនៅកម្ពុជា ក្នុងខែឧសភា ឆ្នាំ២០២៦

ក្នុងខែឧសភា ឆ្នាំ២០២៦ គម្រោងវិនិយោគសរុបដែលត្រូវបានចុះបញ្ជីនៅកម្ពុជាទាំងការចុះបញ្ជីដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) ទាំងការចុះបញ្ជីដោយអនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត (អ.គ.វ.រ.ខ.) មានចំនួន ៣៧ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ៥៧០លានដុល្លារអាម៉េរិក និងអាចបង្កើតការងារបានប្រមាណ២៦ពាន់កន្លែង។ ក្នុងចំណោមគម្រោងវិនិយោគទាំង ៣៧ មានគម្រោងចំនួន ២៩ ក្នុងទំហំទុនវិនិយោគប្រមាណ ៥៤៤លានដុល្លារអាម៉េរិក និងអាចបង្កើតការងារបានប្រមាណ២៣ពាន់កន្លែង ត្រូវបានចុះបញ្ជីដោយ ក.អ.ក. ដែលក្នុងនោះ គម្រោងវិនិយោគនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ១៦, គម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ២ និងគម្រោងវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ១១។ ដោយឡែក គម្រោងដែលត្រូវបានចុះបញ្ជីដោយ អ.គ.វ.រ.ខ. មានចំនួន ៨ ក្នុងទំហំទុនវិនិយោគប្រមាណ ២៧លានដុល្លារអាម៉េរិក និងអាចបង្កើតការងារបានប្រមាណ ២,២ពាន់កន្លែង។

ជាការកត់សម្គាល់ គម្រោងវិនិយោគដែលមានភាពលេចធ្លោជាងគេប្រចាំខែ រួមមាន៖

**កសិកម្ម និង កសិ-ឧស្សាហកម្ម**

គម្រោងវិនិយោគបង្កើតកសិដ្ឋានចិញ្ចឹម និងបង្កាត់ពូជសត្វស្វា
- **ទីតាំង៖** ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
- **ទុនវិនិយោគប្រមាណ៖** ៤០លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ២៨២កន្លែង។

**ឧស្សាហកម្ម**

គម្រោងពង្រីកផលិតកម្ម និងបន្ថែមអគារផលិតកម្មរោងចក្រផលិតស៊ីម៉ងត៍
- **ទីតាំង៖** ស្រុកដងទង់ ខេត្តកំពត
- **ទុនវិនិយោគប្រមាណ៖** ២១០លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៥១២កន្លែង។

**ហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ**

គម្រោងវិនិយោគបង្កើតតំបន់សេដ្ឋកិច្ចពិសេស
- **ទីតាំង៖** ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ
- **ទុនវិនិយោគប្រមាណ៖** ១១៦លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៥១៨កន្លែង។

គម្រោងវិនិយោគបង្កើតតំបន់សេដ្ឋកិច្ចពិសេសសួនឌីជីថលកម្ពុជា
- **ទីតាំង៖** ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
- **ទុនវិនិយោគប្រមាណ៖** ៤២លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ២.០៨០កន្លែង។

# គម្រោងវិនិយោគក្នុង ខែឧសភា ឆ្នាំ២០២៦

ដែលត្រូវបានអនុម័តនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

| គម្រោងវិនិយោគ | ទុនវិនិយោគ | បង្កើតការងារ |
|---|---|---|
| ៣៧ | ៥៧០ | ~២៦៣ពាន់ |
| គម្រោង | លានដុល្លារអាម៉េរិក | កន្លែង |

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាម៉េរិក)



៥០ លាន
កសិកម្ម និង
កសិ-ឧស្សាហកម្ម

១៥៧ លាន
ហេដ្ឋារចនាសម្ព័ន្ធ
និងផ្សេងៗ

៣៦៣ លាន
ឧស្សាហកម្ម

## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| ១. កម្ពុជា | ៦៧,១៩% |
| ២. ចិន | ១៥,៣៤% |
| ៣. ហូឡង់ | ៦,៩៨% |
| ៤. សិង្ហបុរី | ៤,៩៤% |
| ៥. កោះ Marshall | ២,០៩% |
| ៦. កោះ Samoa | ១,០៤% |
| ៧. ឥណ្ឌា | ០,៩៦% |
| ៨. ថៃ | ០,៥៦% |
| ៩. ជប៉ុន | ០,៥៤% |
| ១០. កោះ British Virgin | ០,៣៦% |

## របាយគម្រោងវិនិយោគនៅតាមបណ្ដារាជធានី-ខេត្ត

